U.S. Embassy #1, Street 96, Wat Phnom
Phone: 023-728-258; Fax: 023-728-800
Web: http://cambodia.usembassy.gov
Email: Chreav@state.gov

# PRESS RELEASE

# សេចក្តីប្រកាសព័ត៌មាន

*For Immediate Release*
*2017/002*

*February 2, 2017*

## USAID និងមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍វិស័យកសិកម្ម ចុះកិច្ចព្រមព្រៀង ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា

នៅថ្ងៃទី ២៧ មករា ឆ្នាំ ២០១៧ ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) និងមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍វិស័យកសិកម្ម (IFAD) បានចុះអនុស្សរណៈយោគយល់គ្នាលើកិច្ចសហការការងារ និងការប្តេជ្ញា ដើម្បីគាំទ្រដល់ការធ្វើផែនការយុទ្ធសាស្ត្រវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

អនុស្សរណៈនេះ នឹងពិនិត្យលើការបង្កើននិងអនុម័តគោលនយោបាយ ដែលនឹងធ្វើអោយវិស័យកសិកម្មនៅកម្ពុជាបានប្រសើរឡើង ដែលជាផ្នែកសំខាន់មួយនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស។ វាក៏នឹងជួយដល់ធុរៈកិច្ចទាំងអស់ធ្វើការជាមួយគ្នាកាន់តែប្រសើរឡើង ចាប់ពីកសិករដល់អ្នកធ្វើជំនួញ និងដល់ម្ចាស់អាជីវកម្មក្នុងស្រុក ដើម្បីធ្វើអោយផលិតផលកសិកម្មកម្ពុជា អាចប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងស្រុក និងទទួលបានតម្លៃខ្ពស់។ ទីភ្នាក់ងារ USAID (តាមរយៈកម្មវិធីសន្តិសុខស្បៀងសំរាប់អនាគតនៃរដ្ឋាភិបាលអាមេរិក) និង IFAD (ទីភ្នាក់ងារឯកទេសមួយរបស់អង្គការសហប្រជាជាតិ) នឹងចែករំលែកជំនាញ និងបទពិសោធន៍ដែលទទួលបានពីមនុស្សនិងអង្គការជាច្រើនចម្រុះគ្នា ដែលកំពុងធ្វើការលើវិស័យកសិកម្ម។ ជាចុងក្រោយអនុស្សរណៈនេះ នឹងជួយពង្រីកជំនាញអ្នកឯកទេស ដែលជាអ្នកជួយកសិករបង្កើនទិន្នផល ដោយកែលម្អវិធីសាស្ត្ររបស់ពួកគេ ដើម្បីបំពេញតម្រូវការនៃប្រព័ន្ធកសិកម្មប្រកួតប្រជែងដែលកំពុងកើនឡើង។

លោកស្រីនាយិកាបេសកកម្មនៃទីភ្នាក់ងារUSAIDនៅកម្ពុជា បានមានប្រសាសន៍ថា៖ វិស័យកសិកម្មដែលលូតលាស់និងរស់រវើក គឺមានសារៈសំខាន់សំរាប់ការរីកចម្រើននាពេលអនាគតរបស់ប្រទេសកម្ពុជា។ យើងសង្ឃឹមថា ដោយធ្វើការជាមួយគ្នាយ៉ាងជិតស្និទ USAID និង IFAD អាចជួយកសិករកម្ពុជា ក្នុងការរួមចំណែកដល់សេដ្ឋកិច្ចជាតិមានប្រសិទ្ធិភាពជាងមុន ស្របពេលដែលពួកគេកំពុងជួយក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។

តាមរយៈកម្មវិធី សន្តិសុខស្បៀងសំរាប់អនាគត របស់រដ្ឋាភិបាលអាមេរិក USAID មានគំរោងបណ្តាក់ទុនប្រមាណជា ៤០លានដុល្លាអាមេរិក លើការអភិវឌ្ឍវិស័យកសិកម្មរបស់កម្ពុជានៅរយៈពេល៥ឆ្នាំបន្ទាប់។ IFAD នឹងផ្តល់ជំនួយឥតសំណង និងប្រាក់កម្ចី ដើម្បីគាំទ្រដល់គម្រោងអភិវឌ្ឍន៍វិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានទឹកប្រាក់សរុប ១១៨ លានដុល្លាអាមេរិកក្នុងរយៈពេល៥ឆ្នាំ។

លោក Benoit Thierry នាយកកម្មវិធី IFAD ប្រចាំតំបន់អាស៊ីបាស៊ីហ្វិក បានអោយដឹងថា៖ ជាងពីរទសវត្សរ៍មកហើយ ពួកយើងបានជួយប្រជាជនកម្ពុជាជនបទអោយរួចផុតពីភាពក្រីក្រ ដោយបង្កើនឱកាសក្នុងការកែលម្អការចិញ្ចឹមជីវិតរបស់ពួកគេ។ ការសំរបសំរួលការគាំទ្ររបស់យើងជាមួយដៃគូជាច្រើនដូចជា USAID នឹងក្លាយទៅជាការវិនិយោគដែលមានប្រសិទ្ធិភាព និងការចំណេញសំខាន់ជាងមុន សំរាប់វិស័យកសិកម្មរបស់កម្ពុជា ហើយពួកយើងកំពុងអំពាវនាវឱ្យមានទីភ្នាក់ងារផ្សេងៗទៀតចូលរួមកិច្ចខិតខំប្រឹងប្រែងនេះ។

អនុស្សរណៈយោគយល់គ្នា រវាង USAID និង IFAD មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ និងគ្របដណ្តប់សកម្មភាពរបស់ភ្នាក់ងារទាំងពីរក្នុងរយៈពេល ៥ឆ្នាំ៕

\# \# \#